ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាលដីកា
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០០
ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩
សាលដីកា
លេខ ៦៧ VII
ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០
ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោកស្រី [redacted] ប្រធាន

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោកស្រី [redacted] ចៅក្រមរបាយការណ៍

៥.លោក [redacted] រចៅក្រម

ក្រឡាបញ្ជីសវនាការ

-លោក [redacted]

តំណាងមហាអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ [redacted] សុខា៉ នឹងបណ្តឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សាម៉េត ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រIVន" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

១-ឈ្មោះ [redacted] សុខា៉ ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ទឹកអំពៅ កើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួន [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted]

Scanned with CamScanner

"ស្លាប់" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១នាក់ ទោសពីមុនគ្មាន ជានីតិជន ។ (ជកបណ្តឹងសាទុក្ខ)

២-ឈ្មោះ [redacted] ណៃ ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តតាកែវ ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូនចំនួន ០១ នាក់ ទោសពីមុនគ្មាន ជានីតិជន ។ (អ្នកប្តឹងសាទុក្ខ)

មានលោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិ

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារមរណៈភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចមុខរោងចក្រអិលអេ ផ្លូវបេតុង ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណី៖ ឈ្មោះ [redacted] សាម៉េត ភេទប្រុស អាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ ទីកន្លែងកំណើតកើតនៅ [redacted] ខេត្តតាកែវ អាសយដ្ឋានបច្ចុប្បន្ន [redacted] ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។ ប្តឹងសុំឲ្យផ្តន្ទាទោសជនល្មើសតាមច្បាប់ព្រមទាំងសំណងជម្ងឺចិត្ត ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ។

មានលោក [redacted] រិទ្ធា និងលោក [redacted] វិរៈ ជាមេធាវីការពារសិទ្ធិ

**១.អំពីអង្គហេតុ៖**

កាលពីថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង ១០ និង៣០នាទី ឈ្មោះ [redacted] ចន្ថា ភេទស្រី អាយុ ៣៨ឆ្នាំ កំពុងលក់បាយនៅចំណុចមុខរោងចក្រអិលអេ ផ្លូវបេតុង ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជិតគ្នានឹងឈ្មោះ [redacted] សុខវ៉ា នឹងប្រពន្ធឈ្មោះ [redacted] ណៃ លក់ចេកចៀន បន្ទាប់មក បានឈ្លោះប្រកែកគ្នារឿងឈ្មោះ [redacted] ណៃ ចាក់ទឹកហូរកាត់កន្លែងឈ្មោះ [redacted] ចន្ថា លក់បាយ ហើយឈ្មោះ [redacted] ចន្ថា បានលើកថាសចេកចៀនរបស់ឈ្មោះ [redacted] ណៃ ចាក់ចោល ហើយឈ្មោះ [redacted] ណៃ ក៏យកកូនកាំបិតចុងស្រួច ស្រោបដងជ័រពណ៌ខ្មៅចាក់មកលើឈ្មោះ [redacted] ចន្ថា ចំលើដើមទ្រូងខាងស្តាំក្រោម ក ជាប់នឹងទ្រូងហើយឈ្មោះ [redacted] សុខវ៉ា ជាប្តីបានស្ទុះទៅវាយលើឈ្មោះ [redacted] ចន្ថា បន្ថែមទៀត បណ្តាលឲ្យកូនកាំបិតជ្រុះធ្លាក់លើផ្លូវ រួចក៏យកទៅបោះចោលពីកន្លែងកើតហេតុ បន្ទាប់មកសមត្ថកិច្ចបានទៅដល់ ក៏ឃាត់ខ្លួនបានជាក់ស្តែង ហើយក្រុមគ្រួសារជនរងគ្រោះបានយកឈ្មោះ [redacted] ចន្ថា ទៅសង្គ្រោះនៅមន្ទីរពេទ្យតែឈ្មោះ [redacted] ចន្ថា បានស្លាប់បាត់ទៅហើយ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២០៦ "ង១" ក្រ៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] សុខវ៉ា ភេទប្រុស អាយុ៣៧ឆ្នាំ ជាតជាតិខ្មែរ

ខ-ឈ្មោះ [redacted] ណៃ ភេទស្រី អាយុ៣៥ឆ្នាំ ជាតជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ (ដប់) ឆ្នាំ ។

Scanned with CamScanner

ពិបទ ហិង្សាដោយចេតនាស្ថានទម្ងន់ទោសដោយសារមរណៈភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុច មុខរោងចក្រអិលអេ ផ្លូវបេតុង ភូមិស្លែងរលើង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៤ នៃ ក្រមព្រហ្មទណ្ឌ ។

២-បង្គាប់ឲ្យជនជាប់ចោទ៖

ក-ឈ្មោះ [redacted] សុខវ៉ា ភេទប្រុស អាយុ៣៧ឆ្នាំ ជានជាតិខ្មែរ

ខ-ឈ្មោះ [redacted] ណៃ ភេទស្រី អាយុ៣៥ឆ្នាំ ជានជាតិខ្មែរ

សងសំណងទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉េត ចំនួន ៤០.០០០.០០០ (សែសិប លាន) រៀល ។ ការទាមទារលើសពីនេះបដិសេធចោល តាមមាត្រា ៣៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-វត្ថុចាប់យកមានកាំបិតចុងស្រួចដងពណ៌ខ្មៅចំនួន០១ដើម ត្រូវរឹបអូសតាមមាត្រា ៦២,៦៣ នៃ ក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង២ និង ៣០នាទីរសៀល ចំពោះមុខជនជាប់ចោទ និងមេធាវីការពារសិទ្ធិ ឲ្យជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងឧទ្ធរណ៍លេខ ៥៧៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ របស់ អគ្គព្រះរាជអាជ្ញាអម សាលាឧទ្ធរណ៍ ប្តឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ២០៦ "ង១" ក្រ៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី១ នៃសេចក្តីសម្រេច ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រIVs" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលា ឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ក.បណ្តឹងឧទ្ធរណ៍លេខ ៣៤២ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] សុខវ៉ា និងឈ្មោះ [redacted] ណៃ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិ ច្បាប់ ។

ខ.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៨៧ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ របស់ដើមបណ្តឹង រដ្ឋប្បវេណីឈ្មោះ [redacted] សាម៉េត ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

គ.ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៧៣ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៧ របស់ ឯកឧត្តមអគ្គ ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២០៦ "ង១" ក្រ៣ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ របស់ សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹង រដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៨ ។

-ទុកសិទ្ធិប្តឹងសាទុក្ខតាមច្បាប់ ។

Scanned with CamScanner

-បានឃើញ បណ្ដឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុខរ៉ា ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៩៤ "ក្រ.VS" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សាម៉េត ដែលប្ដឹងមិនសុខចិត្តនឹងសាលដីកាលេខ ៩៤ "ក្រ.VS" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

**២.នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្ដីសន្និដ្ឋានថា ឈ្មោះ [redacted] សុខរ៉ា ពុំបានដាក់សារណាការពារតាម លិខិតជូនដំណឹងអំពីការចុះបញ្ជីសំណុំរឿង និងឱ្យដាក់សារណាការពារ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ និងឈ្មោះ [redacted] សាម៉េត ពុំបានដាក់សារណាការពារ តាមលិខិតជូនដំណឹងអំពីការចុះបញ្ជីសំណុំរឿង និងឱ្យដាក់សារណាការពារ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩ ។ បណ្ដឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សុខរ៉ា និងបណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សាម៉េត ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៤២០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ ។ យល់ឃើញថា ការដែលសាលាដំបូង និងសាលាឧទ្ធរណ៍ បានសម្រេចផ្ដន្ទាទោសលើជនជាប់ចោទនោះ ឃើញថាត្រឹមត្រូវហើយ ដោយហេតុថា ជនជាប់ចោទ បានសម្ដាងថាគ្រាន់តែ ចូលទៅជួយប្រពន្ធ នឹងគ្រាន់តែគ្រវាសកាំបិតមុតសើៗ លើស្បែកតែប៉ុណ្ណោះ ។ ចម្លើយនេះ មិនមានមូលដ្ឋាន និងស៊ីសង្វាក់ និងព្យាសនកម្ម នឹងការលើកឡើងរបស់ដើមបណ្ដឹងនោះទេ ។ យល់ឃើញថា ការដកពាក្យបណ្ដឹងសាទុក្ខរបស់ឈ្មោះ [redacted] សុខរ៉ា យោងតាមមាត្រា ៤៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ជនជាប់ចោទអាចធ្វើការលះបង់នូវការពាក្យបណ្ដឹងសាទុក្ខរបស់ខ្លួនបាន ហើយតុលាការកំពូលនឹងធ្វើការកត់ត្រាការលះបង់បណ្ដឹងសាទុក្ខនេះ ។ ហេតុដូច្នេះ សូមប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

-លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] ណៃ បានធ្វើសេចក្ដីសន្និដ្ឋានថា ខ្លួនចង់បង្ហាញពីការពិតអំពីចេតនា តើកូនក្ដីខ្លួនពិតជាមានចេតនាទុច្ចរិត ក្នុងការប្រើហិង្សាឱ្យជនរងគ្រោះស្លាប់ឬយ៉ាងណា ប៉ុន្តែដោយសារតែអវត្តមានរបស់កូនក្ដីខ្លួន ទើបមិនបានសួរនាំក្នុងពេលសវនាការ ។ ក្រោយពីបានសិក្សាសំណុំរឿងមក យល់ឃើញថាអង្គហេតុនេះ មិនមែនជាបទល្មើស ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដោយសារមរណៈភាពជនរងគ្រោះ ដូចដែលតំណាងមហាអយ្យការធ្វើការចោទប្រកាន់នោះទេ ។ ដោយពិនិត្យទៅលើអង្គហេតុដំបូង នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ ពេលនោះបងប្អូនរបស់ជនជាប់ចោទឈ្មោះ [redacted] ណៃ បានលាងម្ហូរនៅក្បែររោងចក្រ ហើយក៏បានចាក់នោះចោល ស្រាប់តែភាគីជនរងគ្រោះឈ្មោះ [redacted] ចន្ថា មានការខឹង ក៏បានឈ្លោះប្រកែកគ្នាទៅវិញទៅមក ហើយក៏បានស្ងប់ទៅវិញ ។ ស្រាប់តែមួយសន្ទុះក្រោយមក ឈ្មោះ [redacted] ចន្ថា បានដើរសំដៅមកតូបរបស់កូនក្ដីខ្លួន ដែលកំពុងតែលក់ចេកចៀន ដំឡូងចៀន និងម្ហូរ ហើយក៏លើកថាសចេកចៀនរបស់កូនក្ដីខ្លួនចាក់ចោល ហើយកូនក្ដីខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ចន្ថា ថាកុំឱ្យធ្វើអ៊ីចឹង ប៉ុន្តែនៅតែមិនស្ដាប់ ។ នៅអំឡុងពេលនោះ ក្នុងដៃកូនក្ដីខ្លួន

Scanned with CamScanner

កំពុងតែកាន់កូនកាំបិតចុងស្រួច ដើម្បីចិតជំឡូងចៀន ក៏បានយកកាំបិតនោះក្រវាស់ដើម្បីការពារខ្លួន ក្នុងគោលបំណង កុំឱ្យឈ្មោះ [redacted] ចន្ថា ធ្វើការបំផ្លាញរបស់ខ្លួនទៀត ប៉ុន្តែដោយហាមមិនស្តាប់ ទើបកូនក្តីខ្លួនធ្វើការសម្រុកចូល ទើបធ្វើឱ្យកូនកាំបិតនោះត្រូវឈ្មោះ [redacted] ចន្ថា ។ ក្នុងពេលនោះដែរ ភាគីទាំងសងខាងមានការប្រតាយប្រតប់គ្នា ដែលមានទាំងប្តីចូលរួមផងក្នុងគោលបំណងបំបែកចេញពីគ្នា ប៉ុន្តែជាអកុសលបែរជាធ្វើឱ្យកាំបិតនោះ ទៅជាប់នឹងដើមទ្រូងរបស់ជនរងគ្រោះទៅវិញ ហើយក្រោយពេលយកទៅមន្ទីរពេទ្យក៏បានស្លាប់បាត់បង់ជីវិត ។ ឃើញថាអង្គហេតុដំបូងឡើយគឺជនរងគ្រោះជាអ្នកបង្ករឡើងដោយខ្លួនឯង ហើយកូនក្តីខ្លួនឈ្មោះ [redacted] ណៃ មិនមានចេតនាទុច្ចរិត ក្នុងការប្រើហិង្សាដោយធ្វើឱ្យជនរងគ្រោះស្លាប់នោះទេ ក្នុងអំឡុងពេលនោះ គឺកូនក្តីខ្លួនគ្រាន់តែការពារខ្លួន និងទ្រព្យរបស់ខ្លួនតែប៉ុណ្ណោះ ។ សូមក្រុមប្រឹក្សាមេត្តាពិនិត្យលើបញ្ញត្តិមាត្រា ២២៤ នៃក្រមព្រហ្មទណ្ឌថា តើកូនក្តីខ្លួនមានចេតនាទុច្ចរិតក្នុងការប្រើហិង្សាដែរឬទេ ហើយជម្លោះដែលបានកើតឡើងនោះ ក៏បានស្ងប់ទៅវិញផងដែរ ប៉ុន្តែជនរងគ្រោះជាអ្នកបង្ករឡើងដោយខ្លួនឯង ហើយបានដើរពីម្ខាងផ្ទាល់មករករឿងកូនក្តីរបស់ខ្លួន ព្រមទាំងបានលើកថាសចេកចៀនរបស់កូនក្តីខ្លួនយកទៅចាក់ចោល មិនតែប៉ុណ្ណោះ កូនក្តីខ្លួនក៏បានធ្វើការហាមទៅលើជនរងគ្រោះផងដែរ ប៉ុន្តែជនរងគ្រោះមិនព្រមស្តាប់នោះទេ ។ ក្នុងបញ្ញត្តិមាត្រា ៣៣ ក៏បានចែងផងដែរថា បុគ្គលណាដែលប្រព្រឹត្តបទល្មើស ក្នុងសភាពការពារស្របច្បាប់ មិនទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌនោះទេ ។ យោងតាមអង្គហេតុនេះ ឃើញថាជនរងគ្រោះបានមកធ្វើការឈ្លានពាន ដល់រូបកាយ ទីតាំង និងទ្រព្យសម្បត្តិរបស់កូនក្តីខ្លួន ។ ហេតុដូច្នេះ ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យកូនក្តីរបស់ខ្លួន ស្នើសុំក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិនិត្យ និងពិចារណា អំពីអង្គហេតុ និងអង្គច្បាប់ ដែលពាក់ព័ន្ធទៅនឹងបញ្ញត្តិការការពារខ្លួនស្របច្បាប់ និងសំណូមពរឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉េត ឆ្លើយថា មុននឹងកើតហេតុ ខ្លួន និងប្រពន្ធកំពុងរៀបចំតូបដើម្បីធ្វើការលក់ នៅពេលនោះជនជាប់ចោទកំពុងតែលាងម្ជូរនៅផ្លូវម្ខាងទៀត ហើយការចាក់ទឹកនេះមិនមែនទើបតែចាក់នោះទេ គឺបានធ្វើការចាក់ច្រើនដងមកហើយ តែខ្លួនមិននិយាយអ្វីទេ ដោយសារតែនឹកឃើញថាធ្វើការលក់ដូរដូចគ្នា ហើយដោយសារខ្លួនមិនសូវមាត់ ភាគីម្ខាងទៀតក៏តែងតែចាក់ទឹកបង្ហូរ ។ ដោយសារតែខាងខ្លួនទាបជាង ហើយបើប្រសិនបើនៅពេលខ្លួនព្យូរបាយ និងសម្លជ្រុះទៅ ធ្វើឱ្យប្រឡាក់ភក់ ដូច្នេះអ្នកធ្វើការរោងចក្រមិនទិញនោះទេ ទើបខ្លួនខឹងហើយនិយាយថា ប្រសិនបើលាងហើយកុំចាក់អីព្រោះខាងខ្លួននៅខាងទាបជាង ស្រាប់តែជនជាប់ចោទថា ខ្លួនចាក់លើផ្ទាល់ទេ មិនបានចាក់នៅផ្ទះរបស់ដើមបណ្តឹងរដ្ឋប្បវេណី នោះទេ ស្រាប់តែខ្លួនខឹង ក៏បានជេរប្រមាថគ្នាទៅវិញទៅមក ។ ក្រោយមកប្រពន្ធរបស់ខ្លួនក៏បានទៅសួរនាំថា ហេតុអ្វីបានជាចេះតែចាក់ទឹករហូតអ៊ីចឹង ជនជាប់ចោទក៏បានឆ្លើយតបថា ខ្លួនចាក់មិនបានទើសក្បាលអ្នកណានោះទេ ។ បន្ទាប់មកជនជាប់ចោទ បានធ្វើការគំរាមថានឹងជះទឹកខ្លាញ់មកលើប្រពន្ធរបស់ខ្លួន ដោយសារខ្លាចជនជាប់ចោទជះខ្លាញ់លើ ប្រពន្ធខ្លួនក៏បានទាញថាសជំឡូងរង បណ្តាលឱ្យជំឡូងទាំងអស់នោះជ្រុះទៅលើផ្ទាល់ ។ ដោយជនជាប់ចោទឈ្មោះ [redacted] ណៃ មានកាំបិតនៅក្បែរខ្លួនក៏យកមកគប់ជាប់ទៅលើដើមទ្រូងខាងស្តាំងប្រពន្ធរបស់ខ្លួន ហើយប្តីរបស់ជនជាប់ចោទឈ្មោះ [redacted] សុខវ៉ា ឃើញបែបនេះ ក៏បានស្ទុះមករុញបន្ថែមកាំបិតដែលចាក់លើដើមទ្រូងប្រពន្ធរបស់ខ្លួន រួចក៏បានដកកាំបិតនោះបោះចោលនឹងកន្លែងកើតហេតុតែម្តង ។ សំណូមពរឱ្យដាក់ទោសទៅលើជនជាប់ចោទ ។

Scanned with CamScanner

-លោក [redacted] វីរៈ ជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សាម៉េត បានធ្វើសេចក្ដីសន្និដ្ឋានថា អង្គហេតុខាងលើនេះ គឺកើតឡើងចេញពីអំពើហិង្សា និងការជេរប្រមាថគ្នាទៅវិញទៅមក ប៉ុន្តែដោយសារតែទប់ស្កាត់នូវសកម្មភាពមិនបាន ទើបបណ្ដាលឱ្យមានមរណៈភាពនៃជនរងគ្រោះ ។ ដោយផ្អែកតាមភស្តុតាង និងវីដេអូឃ្លីប នៅក្នុងសំណុំរឿង ដែលមានជនជាប់ចោទឈ្មោះ [redacted] សុខា បានធ្វើការដកបណ្ដឹងសាទុក្ខនេះ គឺជាជនដៃដល់ ដែលបានសម្លាប់ជនរងគ្រោះតែម្ដង ។ ផ្អែកតាមចម្លើយ និងសំណូមពរ របស់កូនក្ដីខ្លួន គឺកូនក្ដីខ្លួនមិនសុខចិត្ត ទៅនឹងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលបានតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ លើសំណងជំងឺចិត្ត ៤០,០០០,០០០ (សែបសិបលាន) រៀល គឺកូនក្ដីខ្លួនសូមទាមទារសំណងជំងឺចិត្ត និងការខូចខាតផ្សេងៗ សរុបចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ។ សំណូមពរ សូមឱ្យក្រុមប្រឹក្សា សម្រេចបង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដោយចង្អុលបង្ហាញ ពិនិត្យ និងពិចារណាអំពីការទាមទារសំណងរបស់កូនក្ដីខ្លួន ។

- ក្រោយពីបានស្ដាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានសុំរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៣ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] សុខា និងបណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាម៉េត ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃនីតិវិធីព្រហ្មទណ្ឌ ។

២-យល់ឃើញថា ដើមបណ្ដឹងសាទុក្ខឈ្មោះ [redacted] សុខា បានសុំដកពាក្យបណ្ដឹងសាទុក្ខរបស់ខ្លួនតាមពាក្យសុំចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ រួចហើយ ដូចនេះ តុលាការកំពូលមិនលើកយកមកពិចារណាទៀតទេ ។

៣-យល់ឃើញថា ឈ្មោះ [redacted] សាម៉េត ជាដើមបណ្ដឹងរដ្ឋប្បវេណី បានប្ដឹងទាមទារសំណង និងជម្ងឺចិត្តចំនួន ៥០.០០០$ (ប្រាំម៉ឺន) ដុល្លារអាមេរិក នោះតុលាការកំពូលពិនិត្យឃើញថាមានចំនួនច្រើន បើគិតពីស្ថានភាពរបស់ជនជាប់ចោទ ។ ម្យ៉ាងទៀតរឿងហេតុដែលកើតឡើងនេះ ក៏មានចំណែកនៃការទទួលខុសត្រូវរបស់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ។ ការដែលសាលាឧទ្ធរណ៍សម្រេចលើសំណងជួសជុលការខូចខាត និងជម្ងឺចិត្តមានភាពសមល្មមហើយ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៩៤ "ក្រIVន" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ដែលសម្រេចសេចក្ដីមកនេះ ត្រឹមត្រូវហើយ ។

Scanned with CamScanner

ហេតុដូច្នេះ

សម្រេច

១. បដិសេធ បណ្ដឹងសាទុក្ខលេខ ២៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] សាម៉េត ។

២. តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៩៨ "ក្រIVន" ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ទុកជាបានការទាំងមូល ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២០។

Scanned with CamScanner